

# ហានិភ័យ យួន នៅ ស្រុកខ្មែរ

នាបច្ចុប្បន្ន នេះ យៀកណាម គេលែងទុកស្រុកខ្មែរជារដ្ឋឯករាជ្យ ព្រោះគ្រប់សន្ធិសញ្ញា ដែលសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៩១) ចុះហត្ថលេខាជាមួយគេ នៅមានធរមានចំពោះគេ ជាពិសេសសន្ធិសញ្ញាឆ្នាំ ១៩៧៩ ដែល អ្នកស្នេហាជាតិ ហុង សុខហួរ យកមកបង្ហាញ ដល់សាធារណជន ថា នៅក្នុងសន្ធិសញ្ញានេះ មានចែងច្បាស់លាស់ថា ខ្មែរ-យៀកណាម រួមគ្នាជាប្រទេសតែមួយ។ ក្នុងគោលការណ៍នេះឯង ដែល ប្រទេសយៀកណាម អនុញ្ញាត ឲជនជាតិគេ ចូលតាមសេរី មករស់នៅក្នុងទឹកដីខ្មែររាប់លាននាក់ គ្មានប្រតិកម្មអ្វីបន្តិចពី របប ហ៊ុន សែន។ ការគ្មានប្រតិកម្មនេះឯង ជា សេចក្តីអនុញ្ញាតដោយតុណ្ហី (ដោយនៅស្ងៀម) ពីសំណាក់ រដ្ឋាភិបាល ហ៊ុន សែន បំពានលើកិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា ១៩៩១។ សន្ធិសញ្ញា បន្ថែម ២០០៥ ជាការបំពានបន្ថែមលើកិច្ចព្រមព្រៀង ២៣ តុលា ១៩៩១ និង រដ្ឋធម្មនុញ្ញខ្មែរ នាបច្ចុប្បន្ននេះ។ ដូច្នេះការបោះបង្គោលព្រំដែន ខ្មែរ-យៀកណាម ដោយផ្អែក លើសន្ធិសញ្ញា បន្ថែម ២០០៥ វាផ្ទុយនឹងរដ្ឋធម្មនុញ្ញទាំងស្រុង ហើយការប្រើផែនទី ខុសពីផែនទីដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ជាអំពើក្បត់ជាតិ មិនដូច លោក សុខ ទូច ថាបើគាត់មិនយកផែនទី រដ្ឋាភិបាលមកប្រើប្រាស់ គឺ គាត់ជាអ្នកក្បត់ជាតិ ព្រោះ គ្រប់សន្ធិសញ្ញា ដែល សាធារណរដ្ឋប្រជាមានិតកម្ពុជា ចុះហត្ថលេខាជាមួយប្រទេសយៀកណាម វាក្លាយជាច្បាប់រដ្ឋធម្មនុញ្ញ រួចស្រេចអស់ទៅហើយ ព្រោះមានការទទួលស្គាល់ពីរដ្ឋសភា និង ព្រះមហាក្សត្រខ្មែរ នៅក្នុងឆ្នាំ ២០០៥ តែ លោក សុខ ទូច មិនបានគិតថា គ្រប់ច្បាប់ណា ដែលមានជាតុផ្ទុយពីរដ្ឋធម្មនុញ្ញ ទោះបីច្បាប់ទាំងនោះ មានការបោះឆ្នោតដោយរដ្ឋសភា ហើយ ព្រះមហាក្សត្របានចុះហត្ថលេខា ក៏ដោយ បើមិនធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញ វាជា ច្បាប់ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ជានិច្ច ព្រោះគ្មានជនណា ឬ ស្ថាប័នណាមួយ នៅពីលើច្បាប់បាននោះឡើយ ហេតុនេះឯងបានជា លោក ហ៊ុន សែន មានបំណងធ្វើវិសោធនកម្ម មាត្រាទី២ នៃរដ្ឋធម្មនុញ្ញ ដើម្បីធ្វើឲការប្រើផែនទីរដ្ឋាភិបាល សំរាប់បោះបង្គោលព្រំដែន មានលក្ខណៈត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ មិនមែនដូច លោក សុខ ទូច ថ្លែងថា ដើម្បីឲផែនទីខ្មែរ ឆ្លើយតប នូវគ្រប់ករណី ព្រំដែនទឹកដីខ្មែរ ជាមួយ គ្រប់ប្រទេស ដែលមានព្រំប្រទល់ជាមួយប្រទេសកម្ពុជា។

លោក សុខ ទូច មានសញ្ញាប័ត្រជាបណ្ឌិត ចេញពីប្រភពណាក៏ដោយ ខ្ញុំមិនវាយតម្លៃសញ្ញាប័ត្រ របស់គាត់នោះទេ តែ ងារជាបណ្ឌិត គេទុកជាបញ្ញវន្ត ហើយ បញ្ញវន្ត វាមានមុខងារបីយ៉ាងៈ ផលិត នៃការចេះដឹង (produire du savoir) ; ផលិត នៃជំនាញ

ការ (produire de l’expertise) និង ជាអ្នក ផ្សាយការចេះដឹង ដល់សាធារណជន។ ចំពោះករណី លោក សុខ ទូច គាត់មិនបានបំពេញមុខងារ ទាំងបីយ៉ាងនោះសោះ ក្នុងឋានៈជាបញ្ញវន្ត នាំឲមានជាសំណួរថា តើ លោក សុខ ទូច ជាអ្នកចេះដឹងពិត ឬជា ភ្នាក់ងាររបស់បក្សកុម្មុយនិស្តយួន ពាក់សញ្ញាប័ត្របណ្ឌិត ដើម្បីបំរើប្រយោជន៍បក្ស នៅពេលណាដែលបក្សត្រូវការ ព្រោះនៅក្នុងរបបកុម្មុយនិស្ត គេបង្កើត សញ្ញាប័ត្រ, ស្ថាប័ន ដូចជា រាជបណ្ឌិតសភាខ្មែរ ដើម្បី គ្រប់គ្រង ការចេះដឹង របស់ប្រជាជន ឲស្របនឹងខ្សែបន្ទាត់នយោបាយ របស់បក្ស និង ជា ទូកញ្ចក់ តាំងបង្ហាញ ការចេះដឹង សំរាប់បំភាន់មជ្ឈដ្ឋាននៃបញ្ញវ័ន្ត នៅក្នុង ពិភពលោក។ លទ្ធិកុម្មុយនិស្ត មិនទុក ការចេះដឹង ជា បញ្ញា នៃមនុស្ស ឬ មនុស្សជាតិ នោះទេ គេទុកជាឧបករណ៍ បំរើ បក្ស ដូច្នេះ អ្នកចេះដឹងមិនមែនជាម្ចាស់ នៃចំណេះរបស់ខ្លួននោះឡើយ ព្រោះបក្សជាកម្មសិទ្ធិផ្តាច់មុខ គ្រប់វត្ថុឥតជីវិត, មានជីវិត, ឥតរូប, មានរូប ដែលមានក្នុងលោកីយ និង នៅក្នុង គំនិតរបស់មនុស្ស។ លទ្ធិកម្មុយនិស្ត មិនទុកមនុស្ស ជាមនុស្សមានសម្បជញ្ញៈ តែជាសត្វលោកមានសភាវគតិ អាចលុតដំឲក្លាយជា គ្រឿងយន្ត សំរាប់បំរើលទ្ធិបាន។ លោក សុខ ទូច ជាផលិតផល បរិសុទ្ធ នៃយួនកុម្មុយនិស្ត ក្នុងចំណោមអ្នកចេះដឹង នៅក្នុងរបបហ៊ុនសែនដែលយួនគេបញ្ចេញមកប្រើ នាបច្ចុប្បន្ននេះ ព្រោះយួនមើលឃើញ ថា លោក ហោ ណាំហុង, វ៉ា គឹមហុង ជាអ្នកបំរើ លែងមានប្រយោជន៍ក្នុងផ្នែកគំនិត ដូច្នេះ គេ យក មនុស្សថ្មី មានវ័យក្មេង ពូកែស្រែក មកប្រើបន្ថែម គឺ លោក សុខ ទូច ដែលគ្រាន់ជាកូនឆ្កែមួយដែលយៀកណាម គេឲព្រុសបន្ថែម លើសម្លេងព្រុស របស់ លោក ផៃ សិផាន, ឈាន វុន, វ៉ា គឹម ហុងហោ ណាំហុង, នាង កុយ ពិសី ។ល។

យៀកណាម គេយក កម្លាំងបាយ និងប្រព័ន្ធយុត្តិធម៌ នៅក្នុងស្រុកខ្មែរ ការពារផលប្រយោជន៍គេ ដូច្នេះ កិច្ចការ លោក សុខ ទូច ជា ឧបសាធន (accessoire) ថ្មី នៃយុទ្ធសាស្ត្រ យៀកណាម ព្រោះគេ ត្រូវការពេលវេលាដ៏ខ្លី មួយរយៈទៀត សំរាប់ បន្ត ការលេបកម្ពុជា ឲចប់ជាស្ថាពរ ស្របតាមសន្ធិសញ្ញា ឆ្នាំ ១៩៧៩។ ក្នុងយុទ្ធសាស្ត្រនេះ រដ្ឋាភិបាល ហ៊ុនសែន គ្រាន់តែជាអ្នកឈរមើល រងខ្លះ តែសម្របតាមច្រើនជាង ដើម្បីរស់ក្នុងឋានៈជាបរិវា តែប៉ុណ្ណោះ។

ស្រុកខ្មែរយើង មកដល់ដំណាក់កាលមួយ ដែលប្រហែលជាមិនអាចបង្វិលវិញបាននោះឡើយ បើខ្មែរយើងនៅតែនាំគ្នាគេចវេះ មិនព្រមទុក បញ្ហាខ្មែរ ជាបញ្ហាផ្ទាល់រវាង ខ្មែរ/យៀកណាម ព្រោះ យៀកណាម ជា ហានិភ័យ ដល់ខ្មែរ ដូចយ៉ាង ការបោះបង្គោលព្រំដែនបំពានមកក្នុងទឹកដីខ្មែរ, ការហូរចូលនៃជនជាតិយួនរាប់លាននាក់ មកក្នុងស្រុកខ្មែរ និង ការរក្សា របប ហ៊ុន សែនឲនៅបំរើយៀកណាម បន្តទៅមុខទៀត។

សរសេរដោយ ឧប សៅ សង្ហា
៨ កញ្ញា ២០១៥

សិទ្ធិជ័យ (victoire définitive) របស់ យៀកណាម នៅតែមួយ ជំហោងដៃ តែប៉ុណ្ណោះបើខ្មែរយើង នៅតែរកដំណោះស្រាយតាម រយៈក្រុម លោក ហ៊ុន សែន ព្រោះវាមិនអាចជាដំណោះស្រាយសំរាប់ប្រជាជាតិខ្មែរ វាគ្រាន់តែជាវិធានការ សំរាប់ ឲក្រុម លោកហ៊ុន សែន ជួយរកខ្យល់ ឲក្រុម គាត់ បន្ត ដកដង្ហើម ដើម្បី ធ្វើការបំរើប្រយោជន៍យៀកណាម តែប៉ុណ្ណោះ។ រាល់ការរក ដំណោះស្រាយ តាម ការចរចារ ឬ សន្ទនា ជាមួយ ហ៊ុនសែន គឺ ដូចជានាំគ្នាចាក់ថ្នាំកម្លាំងឲគាត់មានវិរយៈភាព ខ្លាំងក្លា បន្ថែមទៀត ដើម្បីសម្លាប់ខ្មែរតែប៉ុណ្ណោះ។ ឧទាហរណ៍មានជាក់ស្តែង គឺ វប្បធម៌សន្ទនា របស់គណបក្សសង្គ្រោះជាតិ គឺនាំមកតែ ព្យាកុលភាព (ភាពមិនច្បាស់) នៅក្នុងជួរអ្នកស្នេហាជាតិ ក្នុងការតស៊ូប្រឆាំងនឹងរបបផ្តាច់ការ តែប៉ុណ្ណោះ។ នយោបាយណា ដែលយក ក្រុម ហ៊ុន សែន ជាដៃគូ គឺជានយោបាយ បំផ្លាញជាតិ ព្រោះក្រុម ហ៊ុន សែន មិនអាចឈប់បំរើយួនបាននោះឡើយ ព្រោះការនេះ ជារឿង «ស្លាប់ រស់ របស់ ហ៊ុន សែន»។

នយោបាយណា ដែលរង់ចាំ មហាអំណាច ណាមួយ ថាគេនឹងជួយខ្មែរ ដើម្បី យកឈ្នះតាមវិធីបែបណាក៏ដោយ លើ ក្រុម ហ៊ុន សែន គឺ ជា មាយាការ (ការភាន់) បន្តជានិច្ច ព្រោះ មហាអំណាច ជាពិសេស មហាអំណាច លោកសេរី គេមិនគាំទ្រជាដាច់ខាតគណបក្សនយោបាយ ណាមួយឡើយ នៅក្នុងទំនាស់ផ្ទៃក្នុង របស់ប្រទេសមួយ។ ហើយការលើកយកមកនិយាយ ថា មានមហាអំណាច គេចាំជួយខ្មែរ តាមរយៈ ផែនការ ដោយមានអ្នកជំនាញការមកជួយរៀបចំ នៃការអភិវឌ្ឍន៍ ជាតិ ជា សំដីគ្មានទទួលការខុសត្រូវ នាំបង្ហាញ នូវអសមត្ថភាព នៃអ្នកដឹកនាំជាតិខ្មែរ។ សំដីនេះ ជាសំដី មិនបង្កើតមោទនភាពជាតិខ្មែរនោះឡើយ។ ត្រូវដឹងថា ប្រជាពលរដ្ឋខ្មែរ រង់ចាំ មហាអំណាច អស់ច្រើនទស្សវត្សរ៍ មកហើយ មកជួយខ្លួន ឲចេញផុតពីហានិភ័យយួន តែមួយឆ្នាំទៅមួយឆ្នាំ ជនជាតិយួនកាន់តែហូរចូលស្រុកខ្មែរ កាន់តែច្រើនឡើងៗ។ ការពិតសំរាប់ខ្មែរគឺ ហានិភ័យយួន បើខ្មែរនៅតែមិនព្រមយល់ដឹង ហានិភ័យនេះទេ គឺ ប្រជាពលរដ្ឋខ្មែរជាអ្នកទទួលខុសត្រូវនៅចំពោះមុខប្រវត្តិសាស្ត្រ។ ក្នុងកាលៈទេសៈ នេះ ខ្មែរមិនត្រូវទុកខ្មែរគ្នាឯងជាសត្រូវ តែខ្មែរត្រូវទុកជនណា ដែលធ្វើសកម្មភាពបំផ្លាញជាតិខ្មែរ ជាសត្រូវរបស់ប្រជាជាតិខ្មែរ។

សរសេរដោយ ឧប សៅ សង្ហា
៨ កញ្ញា ២០១៥